# មជ្ឈមណ្ឌលឯកសារកម្ពុជា

**PTI0064**

## សម្ភាសន៍ជាមួយឈ្មោះ គឹម ឡៃ ភេទស្រី អាយុ៥៣ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហម“បុគ្គលិកពេទ្យ”
## ស្រុកកំណើតនៅភូមិថ្មក្រែ ឃុំថ្មក្រែ ស្រុកក្រចេះ ខេត្តក្រចេះ
## រស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់
## ថ្ងៃទី២១ខែឧសភា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## ០០ៈ៥៧ៈ០០
## ៣១ទំព័រ

វណ្ណៈ ចឹងថ្ងៃហ្នឹងថ្ងៃទី២១ខែ៥ឆ្នាំ២០១១ ចាំមីងជួយនិយាយពុបន្តិចមីងណា ខ្ញុំឈ្មោះសុខ វណ្ណៈ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាហើយមកដល់ភូមិឃុំមីងនេះ គឺចង់ដឹងរឿងរ៉ាវដែលបងប្អូនយើងធ្លាប់ឆ្លងកាត់កន្លងមកជួបការលំបាកយ៉ាងម៉េច បានសុខទុក្ខយ៉ាងម៉េចហើយភូមិសាស្រ្តនៅវាលវែងហ្នឹង មានលក្ខណៈយ៉ាងម៉េច បងប្អូនមកដល់ឥឡូវហ្នឹងរកស៊ីអីខ្លះ ហើយប្រកបមុខរបរធ្វើស្រែចំការហ្នឹងមានការរីកចំរើនយ៉ាងម៉េច មានការអភិវឌ្ឍន៍យ៉ាងម៉េចមីងណាស់ ។

ឡៃៈ ចាស ។

វណ្ណៈ ហើយចឹងបទសម្ភាសខ្ញុំជាមួយមីងហ្នឹង ខ្ញុំយកទៅចងក្រងឲ្យក្មេងជំនាន់ក្រោយបានដឹងបានពុដែលមីងណាស់ ។

ឡៃៈ ចាស ។

វណ្ណៈ ចឹងមីងឆ្លើយឲ្យពុៗមន្តិចឆ្លើយចឹងអត់ពុទេ?

ឡៃៈ ចឹងខ្ញុំសុំឆ្លើយនិយាយទៅតាំងពីរស់នៅស្រុកវាលវែងនេះ ខ្ញុំនៅជំនាន់កាលហ្នឹងឆ្នាំ៩០យី៩៨ ។

វណ្ណៈ បាទ!មិនអីទេចាំខ្ញុំសួរមីង ។

ឡៃៈ សួរពីឆ្នាំណាមកឆ្នាំណា ។

វណ្ណៈ មិនអីទេ ចាំខ្ញុំសួរមីងបើមីងឆ្លើយបានឆ្លើយបើឆ្លើយមិនបានមិនបាច់ឆ្លើយក៏អត់អីដែរ?

ឡៃៈ ចាស ។

វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ មីង មីងឈ្មោះអី?

ឡៃៈ ខ្ញុំឈ្មោះ គឹម ឡៃ ។

វណ្ណៈ	ចឹងមីងអាយុប៉ុន្មានហើយ?

ឡៃ	ខ្ញុំអាយុ៥៣ហើយ ។

វណ្ណៈ	ប្ដីមីងឈ្មោះអីដែរ?

ឡៃ	ប្ដីខ្ញុំឈ្មោះ ជ័យ សារី ។

វណ្ណៈ	ចឹងគាត់មានអាយុប៉ុន្មានដែរ?

ឡៃ	អាយុគាត់គិតទៅ គាត់កើតឆ្នាំ១៩៥៥ បើគិតទៅគាត់៥៥-៥៦ហើយ ។

វណ្ណៈ	បាទ!ចឹង៥៦?

ឡៃ	ចាស ។

វណ្ណៈ	ចឹងមីងមានកូនទាំងអស់ប៉ុន្មាននាក់?

ឡៃ	កូនខ្ញុំទាំងអស់មាន៥នាក់ ។

វណ្ណៈ	ស្រីប៉ុន្មាន?

ឡៃ	ស្រី២ប្រុស៣ ។

វណ្ណៈ	ចឹងឪពុកបង្កើតមីងឈ្មោះអីដែរ?

ឡៃ	ឪពុកខ្ញុំឈ្មោះ គង់ គីប ។

វណ្ណៈ	ម្ដាយ?

ឡៃ	ម្ដាយឈ្មោះ ប៉ាន់ សាមីន ។

វណ្ណៈ	ប៉ាន់ សាមីន?

ឡៃ	ចាស ។

វណ្ណៈ	ចឹងសព្វថ្ងៃគាត់នៅរស់ដែល?

ឡៃ	សព្វថ្ងៃគាត់នៅរស់ តែឪពុកខ្ញុំគាត់អាពាធហើយ ។

វណ្ណៈ	ចឹងឪពុកស្លាប់?

ឡៃ	អត់ស្លាប់ទេ ឈឺរាំរ៉ៃអាពាធងើបមិនរួចទេ ទាល់តែលើកគ្រា ។

វណ្ណៈ	បាទ!ចងបងប្អូនបង្កើត?

ឡៃ	បងប្អូនបង្កើតខ្ញុំមានតែពីរនាក់ទេ ប្រុសមួយស្រីមួយខ្ញុំបងគេប្អូនខ្ញុំប្រុស ។

វណ្ណៈ	ចឹងនៅរស់ទាំងអស់ទេ សព្វថ្ងៃហ្នឹង?

ឡៃ	ចាស!មួយនៅស្រុកនោះ ។

វណ្ណៈ	បាទ!ចឹងនៅស្រុក?

ឡៃ៖	ចាស ។

វណ្ណៈ	ស្រុកកំណើតមីងនៅភូមិអី?

ឡៃ៖	ស្រុកកំណើតខ្ញុំនៅភូមិថ្មគ្រែ ។

វណ្ណៈ	ស្រុកកំណើត?

ឡៃ៖	ចាស!ស្រុកកំណើតនៅខេត្តក្រចេះ ។

វណ្ណៈ	នៅភូមិអី?

ឡៃ៖	ភូមិថ្មគ្រែ ។

វណ្ណៈ	ឃុំ?

ឡៃ៖	ឃុំថ្មគ្រែដែរ ។

វណ្ណៈ	ស្រុក?

ឡៃ៖	ស្រុកក្រចេះ ខេត្តក្រចេះ ។

វណ្ណៈ	ស្រុកក្រចេះនៅទីរួមខេត្ត?

ឡៃ៖	ចាស!នៅភូមិថ្មគ្រែ ឃុំថ្មគ្រែ ។

វណ្ណៈ	ចឹងសព្វថ្ងៃ?

ឡៃ៖	សព្វថ្ងៃខ្ញុំនៅវាលវែងហ្នឹង ។

វណ្ណៈ	នៅភូមិ?

ឡៃ៖	នៅភូមិប្រម៉ាយ ឃុំក៏ប្រម៉ាយដែរ ។

វណ្ណៈ	ស្រុក?

ឡៃ៖	ស្រុកវាលវែង ខេត្តពោធិសាត់ ។

វណ្ណៈ	ចឹងសព្វថ្ងៃមីងប្រកបមុខរបរអី?

ឡៃ៖	ខ្ញុំរាល់ថ្ងៃប្រកបរបរធ្វើចំការនិងអាជីវកម្មតិចតួចហ្នឹង គ្រាន់ដោះដូរជីវភាពប្រចាំថ្ងៃ ។

វណ្ណៈ	ចឹងធ្វើចំការ?

ឡៃ៖	ចាស!ធ្វើចំការដាំពោត ដាំស្រូវហូប ។

វណ្ណៈ	បាទ!ចឹងមីងមានបានរៀនសូត្រទេ កាលពីតូច?

ឡៃ៖	ខ្ញុំបានរៀនដល់ថ្នាក់ទី១០ពីសង្គមចាស់ ។

វណ្ណៈ	ចឹងទី១០ចាស់?

ឡៃ៖	ចាស ។

វណ្ណៈ	រៀននៅសាលាណា?

ឡៃ	នៅសាលាភូមិថ្មគ្រែហ្នឹង ។

វណ្ណៈ	ចឹងមីងឈប់រៀនពេលណា?

ឡៃ	ឈប់រៀនមុនរដ្ឋប្រហារ កាលហ្នឹងគេចាប់ទាហានបានឈប់ ។

វណ្ណៈ	ចឹងឈប់មុនរដ្ឋប្រហាមីងឈប់ដោយសារអីគេ?

ឡៃ	ឈប់ដោយសារកាលហ្នឹងជំនាន់គេចាប់ទាហាន ។

វណ្ណៈ	ចឹងមានចាប់ទាហានដែរ?

ឡៃ	ចាស!ចាប់ទាហានជំនាន់លន់ នល់ ។

វណ្ណៈ	ចឹង?

ឡៃ	ចាស ។

វណ្ណៈ	ចឹងនៅពេលឈប់រៀនហើយមីងធ្វើអីទៀត?

ឡៃ	ឈប់រៀនខ្ញុំនៅផ្ទះ ។

វណ្ណៈ	នៅផ្ទះ?

ឡៃ	ចាស!ជួយធ្វើការងារឪពុកម្ដាយ ។

វណ្ណៈ	ចឹងជួយធ្វើការងារឪពុកម្ដាយហើយយ៉ាងម៉េចទៀតមីង?

ឡៃ	ក្រោយមកចឹងទៅគេប្រមូលទៅនៅអង្គភាពនារីចឹងទៅ ។

វណ្ណៈ	អង្គភាពនារីហ្នឹងគេប្រមូលនៅឆ្នាំណា?

ឡៃ	គិតទៅមើលឆ្នាំ ខ្ញុំរកនឹកសិនឆ្នាំ៦៨-៦៩ហ្នឹង ។

វណ្ណៈ	៦៨-៦៩មីងឈប់មកជួយការងារផ្ទះ?

ឡៃ	ចាស!៦៨-៦៩គិតទៅចូលឆ្នាំ៧០ ។

វណ្ណៈ	កាលរដ្ឋប្រហារទម្លាក់សម្ដេចសីហនុហ្នឹង?

ឡៃ	ហ្នឹងហើយ ។

វណ្ណៈ	ចឹងមីងចូលនៅពេលហ្នឹងតែម្ដង?

ឡៃ	ចាស!ចូលហ្នឹងនៅក្នុងភូមិទេ ជាក្រុមនារីចឹងទៅសមាគមន៍នារីចឹងទៅ ។

វណ្ណៈ	ចឹងក្នុងភូមិសមាគមន៍នារី?

ឡៃ	ចាស ។

វណ្ណៈ	ចឹងក្រោយមកទៀតយ៉ាងម៉េចទៅមីង?

ឡៃ៖	ក្រោយមកទៀតឆ្នាំ៧០ហ្នឹងគេឲ្យមកនៅអគ្គភាពស្រុក ។

វណ្ណៈ	ចឹងនៅក្នុងឆ្នាំ៧០ដដែលមកនៅអគ្គភាពស្រុកហើយ?

ឡៃ៖	ចាស ។

វណ្ណៈ	មីងកាលហ្នឹងស្ម័គ្រចិត្តចូលឬមួយគេមកហៅ?

ឡៃ៖	និយាយទៅគេជ្រើសរើសតែម្ដង   ជ្រើសរើសឲ្យតែមនុស្សនារីធំៗហ្នឹងគេជ្រើសរើសមកនៅមុំណា ។

វណ្ណៈ	ចឹងតាមការជ្រើសរើសកាលហ្នឹង?

ឡៃ៖	ចាស ។

វណ្ណៈ	ចឹងយើងមិនអាចគេចនៅផ្ទះបាន?

ឡៃ៖	យើងមិនអាចគេចនៅផ្ទះបានទេ ។

វណ្ណៈ	សូម្បីតែមនុស្សស្រីក៏ដោយមិនបាច់ថាមនុស្សប្រុសទេ?

ឡៃ៖	ចាស ។

វណ្ណៈ	ព្រោះកាលហ្នឹងប្រទេសយើងជាលក្ខណៈសង្គ្រាមទៅហើយ?

ឡៃ៖	ចាស ។

វណ្ណៈ	ពេលមកនៅស្រុកហ្នឹងមីងមកធ្វើធ្វើអីនៅស្រុកហ្នឹង?

ឡៃ៖	កាលហ្នឹងធ្វើស្រែប្រាំងអូន ។

វណ្ណៈ	ចឹងនៅអគ្គភាពស្រុកហ្នឹងធ្វើស្រែដែរ?

ឡៃ៖	ចាស! ធ្វើស្រែអគ្គភាពស្រុកហ្នឹងធ្វើស្រែនៅអី  នៅក្រចេះនៅឆ្គុំអីទេភ្លេចបាត់ហើយ ។

វណ្ណៈ	បាទ ។

ឡៃ៖	ម្ដុំក្រោយអូរឫស្សី ។

វណ្ណៈ	ចឹងបនាប់ពីធ្វើស្រែធ្វើអីទៀត?

ឡៃ៖	ក្រោយមកឆ្នាំ៧១-៧២អីហ្នឹងគេជ្រើសរើសមកនៅពេទ្យ ។

វណ្ណៈ	ចឹង៧១-៧២ចូលពេទ្យវិញ?

ឡៃ៖	ចាស ។

វណ្ណៈ	ពេទ្យស្រុកឬពេទ្យណា?

ឡៃ៖	ពេទ្យតំបន់ ។

វណ្ណៈ	ពេទ្យតំបន់ប៉ុន្មាន?

ឡៃ៖ តំបន់៥០៥កាលហ្នឹង តំបន់៥០៥ខេត្តក្រចេះហ្នឹងអូន ។

វណ្ណៈ ចឹងនៅពេទ្យតំបន់ហ្នឹងបានរយៈពេលប៉ុន្មានទៀត?

ឡៃ៖ ខ្ញុំនៅពេទ្យហ្នឹងរហូតទាល់តែខ្ញុំរត់ ។

វណ្ណៈ ចឹង?

ឡៃ៖ ចាស ។

វណ្ណៈ ចឹងចូលតាំងពី៧១រហូតដល់៧៩តែម្ដងពេទ្យក្រចេះអត់មានមកភ្នំពេញទេ?

ឡៃ៖ អត់ទេ តែខ្ញុំទៅរៀននៅភ្នំពេញបានប៉ុន្មានខែដែលហ្នឹង ។

វណ្ណៈ តែទៅរៀនហើយទៅនៅក្រចេះវិញ?

ឡៃ៖ ចាស! នៅក្រចេះវិញ ។

វណ្ណៈ មករៀនភ្នំពេញបានរយៈពេលប៉ុន្មាន?

ឡៃ៖ គិតទៅខ្ញុំរៀនមធ្យមទី១ម្ដង ។

វណ្ណៈ ម្ដងមានប៉ុន្មានខែ?

ឡៃ៖ ម្ដងគិតទៅកាលហ្នឹងរៀនតែពីរខែទេ ។

វណ្ណៈ កាលហ្នឹងពីណាជាអ្នកបង្រៀនកាលហ្នឹង មានចិនមានអីដែរ?

ឡៃ៖ មានចិនបង្រៀន រៀនដាក់ស្ដែង ។

វណ្ណៈ រៀនដាក់ស្ដែងយ៉ាងម៉េចទៅមីងជួយប្រាប់ផង?

ឡៃ៖ រៀនដាក់ស្ដែងគ្រឹស្ដីរៀនទៅ ឧទាហរណ៍ពិនិត្យអីចឹងអូនស្ដាប់បេះដូង ស្ដាប់សួតយើងរៀនរបៀបសម្រាលកូនអីចឹង យើងរៀនទ្រឹស្ដីហើយយើងរៀនអនុវត្តន៍ដាក់ស្ដែងទៀត ។

វណ្ណៈ ចឹងមីងនៅខាងផ្នែកសម្រាលកូន?

ឡៃ៖ ចាស ។

វណ្ណៈ ឬជំងឺទូទៅដែរ?

ឡៃ៖ និយាយទៅខ្ញុំពីមុនធ្លាប់នៅកន្លែងទូទៅ ដល់ក្រោយមកចឹងគេចាត់តាំងឲ្យមកកន្លែងឆ្មប ។

វណ្ណៈ ចឹងកាលមីងព្យាបាលនៅពេទ្យក្រចេះហ្នឹងប្រធានពេទ្យមានពីណាគេ?

ឡៃ៖ ប្រធានពេទ្យហ្នឹងខ្ញុំចង់ភ្លេចឈ្មោះហើយ បើខ្ញុំស្គាល់ស្គាល់តែបង រស់ហ្នឹងគេយកទៅវៃចោលដែរ ។

វណ្ណៈ ចឹងក្រោយមកចាប់ ឈ្មោះ រស់ហ្នឹងដែរ?

ឡៃ៖ ចាស! ក្រោយមកគេចាប់ខ្លួនគាត់ ព្រោះគាត់ជាអនុធនសិស្ស ។

វណ្ណៈ បាទ ។

ឡៃ៖ កាលជំនាន់ហ្នឹង ។

វណ្ណៈ ហើយក្រោយមកមានពីណាទៀត?

ឡៃ៖ ក្រោយមកប្ដីគាត់បង ឡែមហ្នឹងប្ដីគាត់ខ្ញុំភ្លេចឈ្មោះដែលហើយ ។

វណ្ណៈ ប្ដីបង រស់ហ្នឹង?

ឡៃ៖ អត់ទេ បង រស់ហ្នឹងប្រពន្ធគាត់ផ្សេងឈ្មោះអីទេ ។

វណ្ណៈ ចឹងបង រស់ហ្នឹងប្រុសឬស្រី?

ឡៃ៖ បង រស់ហ្នឹងប្រុស ។

វណ្ណៈ ចឹងក្រោយមកគេចាប់ខ្លួន ក្រោយមកទៀតឈ្មោះ បង ឡែម?

ឡៃ៖ បង ឡែមហ្នឹងស្រីទេ ។

វណ្ណៈ ចឹងបង ឡែមហ្នឹងមកពីខាងណា?

ឡៃ៖ បងឡែមហ្នឹងគាត់នៅក្នុងខេត្តគាត់ជាអ្នកទទួលខុសត្រូវដែរ ។

វណ្ណៈ ចឹងគាត់អ្នកស្រុកក្រចេះដែរ?

ឡៃ៖ ចាស!គាត់មិនមែនជាអ្នកស្រុកក្រចេះទេ មិនដឹងជាមកពីខាងណាទេ ខ្ញុំមិនដឹងដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ បង ឡែមហ្នឹងគាត់ស្រី ប្ដីគាត់ឈ្មោះអីខ្ញុំភ្លេច ។

វណ្ណៈ បាទ!មិនអីទេ ចឹងទី១បង រស់គេចាប់ខ្លួនទៅ បង ឡែមចូលមក?

ឡៃ៖ និយាយទៅនៅទាំងអស់អូន នៅទាំងអស់គ្នាចឹងដូចថាគាត់ប្រធានចឹងអនុប្រធានចឹងណាស់ មានពីរមួយអង្គភាពហ្នឹង ។

វណ្ណៈ ចឹងបង រស់ និងបង ឡែម?

ឡៃ៖ ចាស ។

វណ្ណៈ ចឹងថាចាប់ខ្លួន?

ឡៃ៖ និយាយទៅតាមការពិតបង ឡែមប្រពន្ធបង យ៉ាតខ្ញុំភ្លេចនឹកឃើញ បងយ៉ាតនិងគាត់ប្ដីណាស់ ។

វណ្ណៈ បង យ៉ាតហ្នឹងធ្វើអីដែរ?

ឡៃ៖ គាត់ពីមុនមកពេទ្យពីសង្គមចាស់នោះ ។

វណ្ណៈ ពួកគាត់ហ្នឹងអត់ត្រូវអង្គការចាប់ខ្លួនទេ?

ឡៃ៖ ចាប់តើអូន ។

វណ្ណៈ ចឹងចាប់ទាំងអស់ហ្នឹង?

ឡៃ៖ ចាស!ចាប់ម្ដងចឹងគាត់ដឹងខ្លួនថាគេចាប់ចឹងគាត់រត់គេខ្លួន ។

វណ្ណៈ បាទ ។

ឡៃ៖ ដល់ក្រោយមកហ្នឹងគេចេះបបួងគាត់ចេះលួងលោមគាត់ណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ ឲ្យគាត់វិញត្រឡប់មកនៅអន្តភាពវិញ ដល់យូរៗទៅគាត់ភ្លេចខ្លួនចាប់យកមកដាក់ឃុំសាលាខេត្តទៅ ខេត្តក្រចេះយើងហ្នឹងហើយយកទៅវ៉ៃដុំទារុណកម្មហើយបងប្អូនក៏មិនបានអាចជួយដែរ រាល់ថ្ងៃប្អូនគាត់ធ្វើពេទ្យនៅភ្នំពេញដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ ប្អូនបងយ៉ាតនិងឈ្មោះអីទេ បងនាថបានគាត់ស្គាល់ ។

វណ្ណៈ ចឹងកាលហ្នឹងធ្វើទារុណកម្ម?

ឡៃ៖ ចាស!និយាយទៅបង រស់ហ្នឹងគេចាប់ខ្លួនយកទៅបាត់ខ្លួនរហូត គេចាប់យកទៅរៀនគេថាទៅរៀនចឹង ។

វណ្ណៈ បាទ ។

ឡៃ៖ រៀនបាត់រហូតទៅ ។

វណ្ណៈ ចឹងអន្តភាពពេទ្យនៅខេត្តក្រចេះហ្នឹងទាំងប្រុសទាំងស្រីមានប៉ុន្មានរយនាក់ទៅ?

ឡៃ៖ ខ្ញុំគិតទៅច្រើនដែរ ។

វណ្ណៈ ប្រហែល?

ឡៃ៖ ប្រហែលជា៣០០នាក់ជាង មួយក្រសួងហ្នឹងច្រើនដែរ ព្រោះវាបែងចែកជាបី ។

វណ្ណៈ បាទ ។

ឡៃ៖ មានក្រសួងខាងស្លសេរ៉ូអីណាស់ ផលិតសេរ៉ូមចំហ៊ុយសេរ៉ូអីហ្នឹងមួយកន្លែងទៅ ហើយស្លថ្នាំគ្រាប់មួយកន្លែង ខ្ញុំផ្នែកខាងព្យាបាល ។

វណ្ណៈ បាទ!ចឹងការមើលធ្វើពេទ្យនៅក្រចេះហ្នឹង មើលមានសង្កេតឃើញអ្នកមកព្យាបាលមានអ្នកជំងឺប្រភេទណាទៅ?

ឡៃ៖ និយាយទៅគិតពីជំនាន់នោះ កន្លែងទូទៅវារស់នៅបានតិចដែលណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ ភាគច្រើនជំងឺបើនិយាយទៅ ដូចជាកញ្ជ្រិល ភាគច្រើនគឺដើរគ្រុនច្រើនជាងគេ ហើយស្វាយប្រម៉េះអីហ្នឹង ។

វណ្ណៈ មានស្វាយប្រម៉េះដែរ?

ឡៃ៖ ចាស!មានតើ ហើយជំងឺដូចថា និយាយទៅមានចំរុះមិនមានដើរគ្រុនសំខាន់គិតទៅវាមានដូចថាចាស់ៗវារាំរ៉ៃគឺថាគាត់ចំណាស់ហ្នឹងដូចថាវាពិបាកនិយាយដែរ ភាគច្រើនអ្នកជំងឺទូទៅមិនសូវមានសម្រាកប៉ុន្មានទេ សំខាន់របួសភាគច្រើនតែម្តង ។

វណ្ណៈ ចឹងមានព្យាបាលរបួសវិញ?

ឡៃ៖ ចាស ។

វណ្ណៈ ចឹងជំងឺប្រជាជនឈឺហើមអីមិនសូវមានទេ?

ឡៃ៖ មិនសូវប៉ុន្មានទេ គាត់មកតែមួយអាទិត្យហ្នឹងគាត់ត្រឡប់ទៅវិញ មានអ្នករាំរ៉ៃទាល់តែជំងឺហ្នឹងវាធ្ងន់ធ្ងរណាស់បានៗនៅ ។

វណ្ណៈ ចឹងរបួសវៃជាមួយពួកណា?

ឡៃ៖ របួសហ្នឹងកាលជំនាន់វៃជាមួយយួនអីហ្នឹង ឆ្នាំ៧៨-៧៩ហ្នឹង វៃដូរព្រំដែនព្រំដែនស្ទួលហ្នឹងអូន ។

វណ្ណៈ ឆ្នាំ៧៨-៧៩ហ្នឹងរបួសពេលហ្នឹងមានច្រើនតែម្តង?

ឡៃ៖ ច្រើនណាស់អូនអើយ ។

វណ្ណៈ ចឹងមានស្លាប់មានអីទេ?

ឡៃ៖ និយាយទៅស្លាប់មួយថ្ងៃៗគិតទៅខ្មោចដឹកដល់ឡាននោះ ច្រើនណាស់ ។

វណ្ណៈ ស្លាប់ដោយសាររបួសស្លាប់?

ឡៃ៖ ចាស!របួសស្លាប់ទៅវៃហ្នឹងដល់ឆ្នាំ៧៩ហ្នឹងខ្លាំងជាងគេតែម្តង ខ្ញុំនៅហ្នឹងដល់ក្រោយមកគេដកពីកន្លែងហ្នឹងទៅជួយកន្លែងរបួសអីហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងថ្នាំសង្កូវអីយកមកពីប្រទេសណាដែលមីង?

ឡៃ៖ មានភាគច្រើនគឺបារាំងអូន បារាំងហើយចិនអីហ្នឹង ចិនដូចជាមិនសូវមានទេ មានតែថ្នាំបារាំងហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងយ៉ាងម៉េចបានជាត្រូវជាមួយបារាំងអីដែរ?

ឡៃ៖ មិនដឹងជាថ្នាំហ្នឹងសល់មកពីខាងណា ហើយសេរ៉ូមអីយើងផលិតខ្លួនឯងដល់ថ្នាំជាអំពូលអីមានតែថ្នាំយកមកពីគេ ដូចជាប៉េលីសាលីនអីណា ព្រោះបើពួកថ្នាំផ្សះហ្នឹង ។

វណ្ណៈ ចឹងសៀវភៅធ្វើខ្លួនឯង?

ខ្មៅ៖ ចាស!សៀវភៅខ្លួនឯង។

វណ្ណៈ យកអីធ្វើ?

ខ្មៅ៖ ខ្ញុំមិនបានដឹងដែលសារធាតុរបស់គេ ព្រោះគេរៀនដោយខ្សែកៗខ្ញុំដឹងតែពីព្យាបាលមិនដឹងគេយកពីស្អីមក។

វណ្ណៈ ចឹងជំងឺទូទៅអី កាលមកព្យាបាលមានស្លាប់មានអីទេ?

ខ្មៅ៖ មានដែលអូន។

វណ្ណៈ ចឹងមានដែរ?

ខ្មៅ៖ ចាស!អ្នកសម្រាលកូនក៏អាចមានស្លាប់ដែរ។

វណ្ណៈ យ៉ាងម៉េចចឹង?

ខ្មៅ៖ ស្លាប់ទី១ ឧទាហរណ៍ថាគាត់សម្រាលនៅផ្ទះគាត់យូរ។

វណ្ណៈ បាទ។

ខ្មៅ៖ ទុកនៅផ្ទះគាត់យូរចឹងដល់មកដល់ទៅ ឧទាហរណ៍ជាសុខវះមាត់ស្បូនចឹងទៅហើយដល់មកដល់គាត់អស់ឈាមបញ្ជូនទៅភ្នំពេញជូនអីដាច់ខ្យល់តាមផ្លូវ។

វណ្ណៈ បាទ។

ខ្មៅ៖ ព្រោះការបញ្ជូនរបស់យើងវាមិនងាយណា កាលហ្នឹងមានផ្លូវឡានណា យើងទៅតាមទឹក។

វណ្ណៈ បាទ។

ខ្មៅ៖ មានកាណូត កប៉ាល់អីតាមទឹក។

វណ្ណៈ ចឹងនៅពេទ្យតាមខេត្តអីចឹង ពេទ្យតំបន់អីចឹងកាលហ្នឹងមានពេទ្យចុះពីភ្នំពេញទៅដែលត្រួតពិនិត្យមានអ្នកធំចុះទៅដែលមីង?

ខ្មៅ៖ បើនិយាយទៅខ្ញុំដូចជាមិនដែលដឹងអូន ថាខ្ញុំនៅតូចតាចដែលនិយាយទៅមានការងាររបស់គេយើងមិនអាចដឹង យើងតូចតាចថាយើងជាសមាជិកគេ យើងមិនសូវអាចដឹងទេ។

វណ្ណៈ បាទ។

ខ្មៅ៖ យើងដឹងតែការងារគេចាត់តាំងប្រចាំថ្ងៃយើងដឹងតែការងាររបស់យើង ធ្វើការងារខ្លួនឯងហ្នឹង យើងអត់មានដឹងពួទេ។

វណ្ណៈ បាទ។

ខ្មៅ៖ ការងាររបស់គេយើងមិនសូវដឹងទេ។

វណ្ណៈ	កាលហ្នឹងមីងអាយុប្រហែលជាប៉ុន្មានដែរ តាមមីងគិត?

ឡៃ៖	តាមគិតកាលហ្នឹងអាយុ១៧ឆ្នាំ ។

វណ្ណៈ	ចឹងច្រើនដែលមិនមែន១៨ទៅ១៩ទេ?

ឡៃ៖	អត់ទេ ។

វណ្ណៈ	ចឹងនៅពេលថ្នាំពេទ្យមានអក្សរបារាំងអីមានគេបញ្ជាឲ្យយើងយកទៅចាក់បើយើងមិនចេះមើលអក្សរបារាំងផង?

ឡៃ៖	បើនិយាយទៅបើសិនជាមានទាល់អ្នកចេះ អ្នកចេះដូចថានិសិត្សពីមុនមកគេធ្លាប់ធ្វើពេទ្យដូចថា ដូចជាបងយ៉ាតអីហ្នឹង ។

វណ្ណៈ	បាទ ។

ឡៃ៖	ដូច្នេះគាត់រៀនតគ្នាចឹងទៅ រៀនដូចថារៀនពេលយប់ចឹងខ្ញុំបានចូលរៀនដែលហ្នឹង ។

វណ្ណៈ	បាទ ។

ឡៃ៖	រៀនពីការប្រើថ្នាំហ្នឹង រៀនដូចជាអក្សរហ្នឹង ។

វណ្ណៈ	បាទ ។

ឡៃ៖	អក្សរថ្នាំចឹងមានដូច“អា” ដូចជាវីតាមីនចឹងយើងយកអក្សរអីមកប្រកបជាមួយអីគេអានថាវីតាមីន ចឹងយើងរៀនទៅតាមហ្នឹងយើងមើលទៅតាមហ្នឹង ។

វណ្ណៈ	ចឹងគេបង្រៀនដែរ?

ឡៃ៖	ចាស ។

វណ្ណៈ	ប៉ុន្តែភាគច្រើនពេទ្យនៅក្នុងសម័យខ្មែរក្រហមគ្រប់គ្រងហ្នឹងគេមិនសូវជ្រើសយកអ្នកចេះដឹងប៉ុន្មានទេ យកទៅធ្វើពេទ្យមីង?

ឡៃ៖	ចាស!មានតែអ្នកទទួលខុសត្រូវរួមហ្នឹង គេអាចចេះជ្រៅជ្រះជាងគេហើយគេអាចបណ្តុះបណ្តាយយើងតែអ្នកចេះហ្នឹងភាគច្រើនមិនបាននៅយូរទេ ។

វណ្ណៈ	ចឹងមិនបាននៅយូរទេ?

ឡៃ៖	ចាស!បើសិនជាយើងបង្កប់ខ្លួនថាយើងមិនអាចស្រាវជ្រាវឲ្យគេដឹង ថាយើងហ្នឹងជាអនុធននិស្សិតឬមួយក៏អ្នកចេះខាងពេទ្យពីមុនមកណាស់ ចឹងគេយកអាចនិងយកយើងទៅនៅការដ្ឋានអីចឹងទៅ ។

វណ្ណៈ	ចឹងពួកហ្នឹងច្រើនបាត់ខ្លួន?

ឡៃ៖	ចាស!ច្រើនតែបាត់ខ្លួនដូចជាប្តីខ្ញុំ គាត់លាក់បាន ។

វណ្ណៈ ចឹងប្តីមីងធ្វើពេទ្យដែរ?

ខ្មៅ ប្តីខ្ញុំអត់ទេ គាត់អត់មានធ្វើពេទ្យផង ស្រុកកំណើតគាត់នៅខាងនេះវិញ នៅខាងកៀនស្វាយ កោះដែកដោ ។

វណ្ណៈ គគីរធំ?

ខ្មៅ គគីរធំ គាត់ធ្វើកងទ័ព ។

វណ្ណៈ បាទ ។

ខ្មៅ នៅខាងរតនៈគីរីយើងហ្នឹង ។

វណ្ណៈ នៅខាងហ្នឹងគេចាត់ទុកថានៅខាងបូព៌អីដែរ?

ខ្មៅ ចាស ។

វណ្ណៈ គ្រោះថ្នាក់ដែលកាលសម័យហ្នឹង?

ខ្មៅ ចាស ។

វណ្ណៈ ចឹងនៅពេទ្យកាលហ្នឹងបុគ្គលិកពេទ្យទាំងអស់ហ្នឹងការហូបចុកអត់មានលំបាកទេ កាលហ្នឹង?

ខ្មៅ ចាស!ពីមុនមកអត់អីទេហូបចុកអីធម្មតាតែដល់ក្រោយឆ្នាំ និយាយទៅគេចងក្រងជាសមាគម លំបាកហូបដែរ យើងឆ្នាំដូចថាឆ្នាំ៧៨អីហ្នឹង គេចែកជាឆ្នាំងរួមដែលហ្នឹងនិយាយរួមរង្វង់ក្នុង បុគ្គលិក គេហូបដោយឡែកចឹងណាស់ ។

វណ្ណៈ បាទ ។

ខ្មៅ អ្នកជំងឺដោយឡែក តែគេកំណត់ដូចថាអ្នកជំងឺក្នុងមន្ទីរយើងមានគ្នាប៉ុន្មាននាក់ គ្នាប៉ុន្មាននាក់ ហ្នឹងមានគេទៅពិនិត្យទៀតណាស់ ។

វណ្ណៈ បាទ ។

ខ្មៅ មិនមែនយើងចេះតែនិយាយបានទេ ចឹងយើងកំណត់ប៉ុន្មានប្រាប់គេប៉ុណ្ណឹង និយាយទៅរាយ ការណ៍ប្រចាំថ្ងៃតែម្តង អ្នកចូលអ្នកចេញអីត្រូវរាយការណ៍ប្រាប់គេ ចឹងគេកំណត់ឲ្យថាបាយ ឬក៏បបរប៉ុន្មាននាក់ឲ្យយើងណាស់ ។

វណ្ណៈ បាទ ។

ខ្មៅ ឲ្យយើងហូបបានណាស់ ។

វណ្ណៈ បាទ ។

ខ្មៅ ដូចថាបបរ៥នាក់បាយ១០ចឹងមាន១៥នាក់ក្នុងមួយមន្ទីរកន្លែងឆ្នបចឹង ។

វណ្ណៈ បាទ ។

ឡៃ៖ ប៉ុន្តែមានលក្ខណៈខ្លះពួកខ្ញុំក៏អាចរស់បានដែរ បានត្រង់ថាបេះមានអ្នកជំងឺចេញយើងមិនទាន់បានរាយការណ៍ឲ្យចិន ។

វណ្ណៈ បាទ ។

ឡៃ៖ យើងអាចលាក់បានទៅ បានហូបពេលយប់ដល់ពេលអ្នកជំងឺគាត់ឲ្យដូចថាបានមកពីភូមិចិនមានម្ហូបមានមហាអីត្រីសាច់អីចឹង ហូបបានលួចលាក់បាន ។

វណ្ណៈ ចឹងអ្នកជំងឺមានម្ហូបវិញ?

ឡៃ៖ អ្នកជំងឺដូចថាគាត់មកត្រៀមសម្រាលចឹង គាត់មានម្ហូបគាត់មកហើយ ។

វណ្ណៈ បាទ ។

ឡៃ៖ ត្រីសាច់អីរបស់ណាត្រូវហូបបានគាត់ហូប ។

វណ្ណៈ បាទ ។

ឡៃ៖ បើសិនជាប្ដីគាត់យកមកត្រីណាមិនសូវហូបគាត់មិនហ៊ានហូបទេ ។

វណ្ណៈ បាទ ។

ឡៃ៖ ហ្នឹងហើយចឹងគាត់ឲ្យចឹងយកខ្លះទៅ ។

វណ្ណៈ ចឹងកាលហ្នឹងមីងធ្វើពេទ្យត្រឹមខេត្តចឹង ដូចជានៅក្នុងស្រុកភូមិមីងដែលចឹងមីងមានបានទៅលេងផ្ទះអីជួបឪពុកម្ដាយបងប្អូនទេ?

ឡៃ៖ បានតើអូន និយាយទៅបាននៅពេលយើងចុះពលកម្ម ពេលការងារពលកម្មដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ ឧទាហរណ៍ថា ១០ឬមួយអាទិត្យចឹងយើងចែកគ្នា វេនគ្នាចឹងទៅបើខ្ញុំនៅមន្ទីរហ្នឹងខ្ញុំការងារមន្ទីរមានប៉ុន្មាននាក់ ព្រលឹមឡើងការងារក្នុងមន្ទីរដូចថាមួយអាទិត្យចឹង ។

វណ្ណៈ បាទ ។

ឡៃ៖ ព្រលឹមឡើងដឹងថា បោះសម្អាតអ្នកខាងអនាម័យៗ អ្នកខាងគួកគ្រទបចឹងអ្នកជំងឺខាងសម្រាលយើងត្រូវព្រលឹមឡើងប្រមូលក្រទបកូនគាត់យកទៅគួក ។

វណ្ណៈ បាទ ។

ឡៃ៖ មាត់ទន្លេ ។

វណ្ណៈ បាទ ។

ឡៃ៖ បើអ្នកពលកម្មព្រលឹមឡើងដឹងថាម៉ោង៨ ស្រោចទឹកបន្លែហើយ ។

វណ្ណៈ បាទ ។

ខ្មែរៈ ក្នុងមួយថ្ងៃបែកចែកជាពីរចឹង ប៉ុន្តែអ្នកក្នុងមន្ទីរព្រលឹមឡើងត្រូវតែសម្អាតក្នុងបរិវេនក្នុងបន្ទប់ ។

វណ្ណៈ បាទ ។

ខ្មែរៈ ចាស!បោះប្រាសសម្អាតហើយយើងត្រូវ ឲ្យតែភ្លឺឡើងយើងចាប់ផ្តើមសារាំង ។

វណ្ណៈ បាទ ។

ខ្មែរៈ ដាក់ស្ទោហើយទុកព្យាបាលតាមបន្ទប់រៀងៗខ្លួន ។

វណ្ណៈ ចឹងមានអ្នកជំងឺចេញចូលមកធម្មតាចឹង មានចេញមានចូលចឹង?

ខ្មែរៈ ចាស!មានចេញមានចូលបន្តបន្ទាប់គ្នា ។

វណ្ណៈ បាទ ។

ខ្មែរៈ ប៉ុន្តែករណីខ្វះជំងឺធ្ងន់ចឹងយើងបញ្ជូនទៅភ្នំពេញទៅអីចឹង ។

វណ្ណៈ ចឹងកាលហ្នឹងអត់មានដឹកតាមឡានបានទេ មានតែតាមទូក?

ខ្មែរៈ ចាស!តាមកាណូត កប៉ាល់ ។

វណ្ណៈ ចឹងហេតុយ៉ាងម៉េចបានជាមិនមានឡានជំនាន់ហ្នឹង?

ខ្មែរៈ មូលហេតុកាលហ្នឹងយើងមានស្ពានអីណា វាមិនមានស្ពានឆ្លងទន្លេ ។

វណ្ណៈ អូ!មែន ។

ខ្មែរៈ ចាស!យើងអត់មានស្ពានទេ យើងទើបមានស្ពានឥឡូវ ។

វណ្ណៈ ស្ពានជ្រោយចង្វារឆ្លងអត់បាន?

ខ្មែរៈ ស្ពានជ្រោយចង្វារអី ស្ពានទន្លេបិតហ្នឹងកំពង់ចាមហ្នឹង ។

វណ្ណៈ បាទ ។

ខ្មែរៈ ហ្នឹងហើយខ្ញុំធ្លាប់ឆ្លងកាត់ហ្នឹងដែរ ។

វណ្ណៈ បាទ ។

ខ្មែរៈ ចឹងខបស័ក្តមានច្រើនណាស់ ហើយមកជំនាន់៧៩ហ្នឹង គេស្កាត់បាញ់គ្នានៅកន្លែងណាទេ ពួកខ្ញុំក៏បាត់ខ្លួនហ្នឹង ។

វណ្ណៈ បាទ ។

ខ្មែរៈ អត់មានឃើញជូនអ្នកជំងឺតាមទូកណាស់ ។

វណ្ណៈ បាទ!ចឹងខ្ញុំចង់សួរបកទៅសម័យហ្នឹងវិញកាលជំនាន់បីឆ្នាំ តើមីងកាលហ្នឹងដូចជានៅទីក្រុងក្រចេះអីភាពផ្សារអ្វីអរឬមួយមានសភាពស្ងាត់ជ្រងំ?

ឡៃ៖ អូនអើយមានផ្សារពីណាអត់មានទេ ។

វណ្ណៈ អត់មានទេ ជំនាន់ហ្នឹង?

ឡៃ៖ ចាស!មានផ្សារណាយើងអត់មានចាយលុយផង ។

វណ្ណៈ ចឹងអត់មានបរទេសចេញចូលនៅហ្នឹងទេ?

ឡៃ៖ អត់មានទេ ។

វណ្ណៈ អត់មានជនជាតិអីទៅទេ?

ឡៃ៖ អត់មានទេ សុទ្ធតែរបស់គេបើកឲ្យយើងទាំងអស់ ។

វណ្ណៈ បាទ ។

ឡៃ៖ យើងអត់មានប្រាថ្នាថាចង់បានអីទេ គេឲ្យធ្វើអីយើងធ្វើហ្នឹងគេបើឲ្យយើងប្រើខោអាវហរណ៍ថាមួយខែប្រើប៉ុន្មាននៅក្នុងមន្ទីរហ្នឹង ។

វណ្ណៈ បាទ ។

ឡៃ៖ ហើយខោអាវស្លៀកពាក់ក៏ចឹងដែរ មួយឆ្នាំមានប៉ុន្មានកំប្លេ ។

វណ្ណៈ បាទ ។

ឡៃ៖ មិនដូចឥឡូវយើងរកបានយើងចង់ ស្លៀកម៉ូតនេះចង់អាវប៉ាក់ហូរប្រមូលអីអត់ទេ កាលហ្នឹងអូន ។

វណ្ណៈ បាទ ។

ឡៃ៖ ប្រើដូចថាជួរក្នុងពេទ្យហ្នឹង បើតា ស ៗ ខ្មៅ ៗ តែម្តង ។

វណ្ណៈ បាទ ។

ឡៃ៖ ចាស!មួយកំណាត់សមួយកំណាត់ខ្មៅ ចូលធ្វើការ ។

វណ្ណៈ ចឹងពេទ្យមានលក្ខណៈសលើខ្មៅខាងក្រោមចឹងទៅ?

ឡៃ៖ ចាស ។

វណ្ណៈ ចឹងមីងខ្ញុំចង់សួរថា បុគ្គលិកពេទ្យបន្ទាប់ពីគេចាប់ប្រធានៗអីចឹងអ្នកចេះដឹងអីចឹង តើគេមានចាប់បុគ្គលិកពេទ្យធម្មតាអីខុសឆ្គងអីមានទេ?

ឡៃ៖ មាន មានត្រឹមក្រុមមានគេចាប់ដែលតើ ។

វណ្ណៈ ចឹង?

ឡៃ៖ មេក្រុមមេកងអីចឹង មេកងតូចអីណា ។

វណ្ណៈ បាទ ។

ឡៃ៖ គេចាប់ទៅយកទៅដាក់កន្លែងការដ្ឋាន ។

វណ្ណៈ ការដ្ឋានអីគេ?

ឡៃ៖ ការដ្ឋានដូចគេធ្វើពលកម្មចឹងណា ។

វណ្ណៈ ចឹងក្រោយមកពួកហ្នឹងមានស្លាប់មានអីទេ?

ឡៃ៖ និយាយទៅខ្ញុំមិនដឹងដែរ បើបង នាថ ។

វណ្ណៈ តែបើប្រធានធំហ្នឹងគេចាប់ដាក់គុកតែម្តង?

ឡៃ៖ ចាស!ចាប់ដាក់គុក ដាក់គុកហ្នឹងដូចថាគុកយើងហ្នឹងនិយាយទៅគេហៅទៅណែនាំរៀនសូត្រអី ចឹងទៅដូនអីបានឃើញវិញ ដូនអីក៏អត់ដែរ មិនបានឃើញមិនបានជួបគ្នាវិញទេ ដូចបងនាថ បង ដូនេះគាត់នៅជាមួយខ្ញុំដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ ហើយដល់ចឹងគាត់ធ្លាប់ឆ្លងកាត់ព្រោះគាត់នៅកន្លែងស្នូថ្នាំណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ គាត់ស្លូថ្នាំចំហ៊ុយសារ៉ូមអីហ្នឹង ខ្ញុំមកជួបគ្នាបានតែពីរនាក់ហើយដឹង ជួបគ្នាហ្នឹងដោយសារ មានសមាហរណ៍កម្មនេះដែលបានខ្ញុំដឹងថា នៅសល់ពីរនាក់ ។

វណ្ណៈ បាទ ។

ឡៃ៖ ក្រៅពីហ្នឹងបាត់ខ្លួនអស់ហើយ ។

វណ្ណៈ ចឹងនៅខាងខេត្តក្រចេះហ្នឹង គណៈស្រុកគណៈតំបន់អីមានពីណាគេមានស្គាល់ទេ?

ឡៃ៖ កាលហ្នឹងខ្ញុំក្មេចហើយខ្ញុំអត់មានបានចាប់អារម្មណ៍ទេ ទាល់តែបង នាថបានគាត់ស្គាល់ ។

វណ្ណៈ បាទ ។

ឡៃ៖ មានតា ឃី តា គួនមកពីខេត្តតាកែវ ។

វណ្ណៈ គាត់ធ្វើអី?

ឡៃ៖ គាត់ហ្នឹងប្រធានខេត្ត ។

វណ្ណៈ តា ឃី?

ឡៃ៖ ចាស ។

វណ្ណៈ តា ឃី មួយទៀតតា គួន?

ឡៃ៖ ចាស ។

វណ្ណៈ ចឹងពួកមកពីតាកែវពួកគាត់នៅរហូតហើយតាមមើល ព្រោះអីមកចុងក្រោយហើយ?

ឡៃ:	ចាស ។

វណ្ណ:	ប្រហែលជាគាត់អាចរស់ដល់៧៩ រត់ទៅព្រៃអីចឹងដែរ?

ឡៃ:	ចាស ។

វណ្ណ:	ចឹងមានដឹងថា គាត់នៅណាទេ តា យី តា គួនហ្នឹង?

ឡៃ:	អត់ដែលដឹង ។

វណ្ណ:	ចឹងនៅពេលវៀតណាមវៃចូលដល់ទីក្រុងក្រចេះ ខេត្តក្រចេះចឹង?

ឡៃ:	នៅខេត្តក្រចេះខ្ញុំឆ្លងមកនៅក្រោយខាងកើត អះ!ខាងលិច ។

វណ្ណ:	ខាងណាវិញ?

ឡៃ:	ខាងលិចក្រចេះហ្នឹង គេហៅភូមិស្អីទេ ភ្លេចអស់ហើយ រុញគ្នាមករហូតមកនៅនេះរហូតមក នៅម៉ាជួរភ្នំជីនោះ ។

វណ្ណ:	បាទ ។

ឡៃ:	នៅក្នុងព្រៃដោយឡែកអ្នកជំងឺសែង១ទៅនៅក្រោយខាងលិចណាស់ ចឹងអ្នកជំងឺខ្លះគាត់ដើររួច អូចឹងគាត់មិនដឹងជាយ៉ាងម៉េចទេ ព្រោះពេទ្យរត់ចោលអស់ហើយកាលហ្នឹង ។

វណ្ណ:	បាទ ។

ឡៃ:	អត់មានពីណានៅជាមួយ ។

វណ្ណ:	ចឹងកាលហ្នឹងរត់យកអ្នកជំងឺមកតាមដែរ?

ឡៃ:	ចាស!យកអ្នកជំងឺកាលជម្លៀសយើងទៅក្រោយម្ខាងទន្លេ ។

វណ្ណ:	បាទ ។

ឡៃ:	ពីចេះទៅជម្លៀសទៅនៅព្រែកប្រសព្វហ្នឹង ព្រែកប្រសព្វព្រែកគួ ព្រែកស្អីរហូតទៅដល់ស្ទឹង ត្រង់នេះ ។

វណ្ណ:	បាទ ។

ឡៃ:	ដល់ចឹងទៅវៃបុកគ្រប់កន្លែងទៅខ្ញុំមិនដឹងជាស្ថានភាពរបៀបម៉េច ខ្ញុំមិនដឹងដែលព្រោះដឹងតែ គេថាឲ្យប្រមូលកំលាំងពេទ្យសម្រាប់ទទួលអ្នករបួសនៅមុខណាស់ ។

វណ្ណ:	បាទ ។

ឡៃ:	ចឹងមិនថាពេទ្យអីពេទ្យអីទេ តាមគេជ្រើសរើសយកអ្នកណាអីហ្នឹងយើងត្រូវតែទៅបើយើង មិនខ្លាចគេ ជំនាន់ហ្នឹងយើងមិនហ៊ានប្រឆាំងទេ ។

វណ្ណ:	តែកាលវៀតណាមចូលមកបើសិនជាមីងគេចនៅផ្ទះក៏បានដែរ?

ឡៃ៖ គេចនៅផ្ទះព្រោះយើងអត់ហ៊ាន ។

វណ្ណៈ ចឹងអត់ហ៊ាន?

ឡៃ៖ ចាស!ខ្លាចថា តែទៅច្បាស់គេអាករចោលហើយ ។

វណ្ណៈ ចឹងខ្លាចយួនកាលហ្នឹង?

ឡៃ៖ កាលហ្នឹងគេឃោសនាចឹងអូន ព្រោះយើងមិនដែលដឹង មានគេបបួលខ្ញុំទៅដែលតែខ្ញុំអត់ហ៊ាន ទៅខ្ញុំមិនដាច់ចិត្តទៅ នារីៗដូចគ្នាហ្នឹង ។

វណ្ណៈ បាទ ។

ឡៃ៖ គាត់នៅស៊ីងត្រង់ខ្ញុំនៅក្រចេះ ។

វណ្ណៈ ចឹងមានអ្នករត់ទៅផ្ទះវិញខ្លះដែលឬក៏មកភាគច្រើន?

ឡៃ៖ មាន ។

វណ្ណៈ មកព្រំដែនភាគច្រើន?

ឡៃ៖ មានគេរត់ទៅផ្ទះ ទៅផ្ទះហ្នឹងគេអត់ដឹងទេណាស់ ដោយសារគេប្រមូលកំលាំងមកមុខចឹងគាត់ នៅក្រោយគាត់ភ្លេចខ្លួនដែរ ដូចមានអ្នកនាំទៅណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ មានខ្សែរយៈនាំទៅដូចថា អ្នកស្រុកភូមិជាមួយគេហ្នឹងគេនិយាយហ្នឹងដោយសារគេអត់ទាន់ ។

វណ្ណៈ បាទ ។

ឡៃ៖ កំពង់ប្របូកប្របល់ចេះយើងរត់ទៅ ឲ្យតែមានគ្នាដូចថានាំគ្នាទៅចេះតែបានតែយើងចេះតែ ខ្លាច ។

វណ្ណៈ បាទ ។

ឡៃ៖ ខ្លាចតែគេសម្លាប់យើង គេអារកយើងគេមិនទុកជីវិតយើងហ្នឹង គេឃោសនាយើងចេះតែ តាមគេ ។

វណ្ណៈ ចឹងកាលចេះពីក្រចេះហ្នឹងមីងរត់តាមណាខ្លះចេញមកហ្នឹង?

ឡៃ៖ ចេញពីក្រចេះរាប់ទៅនៅមុំភ្នំជីនោះ ទៅដល់ភ្នំជីក្រោយស្ពឺផ្លូវដែប ។

វណ្ណៈ ភ្នំជីខេត្តកំពង់ធំដឹង?

ឡៃ៖ អត់ទេ ។

វណ្ណៈ មិនមែន?

ឡៃ: ខេត្តកំពង់ធំអីម៉ាជួរ និយាយទៅកំពង់ធំហើយព្រោះក្រោយខាងនេះដែរ ផ្លូវដែលទល់មុខអីនេះ សម្បុកសម្បូរណាស់ ។

វណ្ណៈ បាទ ។

ឡៃ: ឡើងទៅលើវិញ ។

វណ្ណៈ បាទ ។

ឡៃ: ហើយបានមកដុំក្រាំងភូមិក្រាំងភូមិអីហ្នឹងឡើងមកត្រៀមស្បៀងឡើងឆ្នាំ៧៩មក កាលហ្នឹងយើងឆ្នាំ៧៩ ចុងឆ្នាំហើយ ។

វណ្ណៈ បាទ ។

ឡៃ: យើងឡើងមកម៉ាជួរភ្នំដងរែក ។

វណ្ណៈ បាទ ។

ឡៃ: កាលហ្នឹងឡើងមកតែ៤០០នាក់ទេ ។

វណ្ណៈ ចឹងមានគ្នាដល់៤០០នាក់?

ឡៃ: ចាស ។

វណ្ណៈ ចឹងរត់មកជុំគ្នារហូតដល់ភ្នំដងរែកឬមានបែកគ្នាតាមផ្លូវតាមផ្លូវអីចឹង?

ឡៃ: អ្នកខ្លះគេនៅប៉ុន្តែកំលាំងគេត្រៀមនៅជួរមុខគេនៅជួរមុខ ដោយឡែកតែកំលាំងពួកខ្ញុំជានារីអីណាស់ ប្រជាជនអីណាហ្នឹងបានឡើងមក បានឡើងមកលើ ។

វណ្ណៈ បាទ ។

ឡៃ: ហើយបើនិយាយទៅឡើងមកលើហ្នឹងខ្ញុំគិតឡើងមកឆ្នាំ៨០ ។

វណ្ណៈ បាទ ។

ឡៃ: ៨០គត់ឡើងមកជួរភ្នំដងរែក ។

វណ្ណៈ ចឹងរត់តាំងពី៧៩រហូតដល់ឆ្នាំ៨០បានដល់ភ្នំដងរែក?

ឡៃ: ចាស!គិតទៅដើរមួយខែ មួយខែបានដល់ កាលជំនាន់ហ្នឹងយើងមិនមានអីហូបទេ មានតែក្តួចដាក់ទៃតែម្តង យើងធ្វើក្តួចសាបហ្នឹងណាស់ ។

វណ្ណៈ បាទ!អត់ពុលទេមីង?

ឡៃ: និយាយពីពុលនោះក៏ពុលដែលអូន យើងធ្វើបើសាបល្អមិនអីទេ ដល់យើងធ្វើអត់ទឹកអត់អីខ្លះទឹកអីខ្វាចយួនរាគត្បាតអីចឹងមានពុល ពុលមានស្លាប់ដោយសារក្តួច ស៊ីអាម៉ើមស្អីនោះចារ

ប្រុសចារហ្នឹងស្លាប់ច្រើន ស្រីៗគិតទៅ៦នាក់ស្លាប់ដោយសារអត់មានបាយស៊ីហើយមកដល់ភ្នំខ្មោចនេះក៏ស្លាប់ច្រើន នៅភ្នំខ្មោចស៊ីអាបបរត្រាវដូរយើងហ្នឹង ត្រាវតាមអូរហ្នឹង ។

វណ្ណៈ បាទ ។

ឡៃ ហើយដាច់អង្ករមានស្លាប់នៅអង្រឹងចឹងដើរទៅមិនរួច កាលហ្នឹងមានកំលាំងទ័ពគេយកមកមីយកអីមកយកអង្ករអីមកចែកគ្នាច្រើនពេក វាពិបាករស់ ។

វណ្ណៈ បាទ ។

ឡៃ ខ្វះគ្នាឈឺផងអីផងណាស់ ។

វណ្ណៈ បាទ ។

ឡៃ ដល់ចឹងទៅវាអត់ទេ នៅស្លាប់ហ្នឹងច្រើនណាស់រាប់រយនាក់ណាស់ ។

វណ្ណៈ បាទ ។

ឡៃ មិនមែនមែនតិចទេណា ស្លាប់គេថាធុមខ្មោច ខ្មោចមែនហ្នឹងខ្មោចស្លាប់នៅអង្គុយផ្អែកដើមឈើស្លាប់ហ្នឹង ដើរដឹកដំឡូងស្លាប់ នៅលើអង្រឹងស្លាប់ក៏ឃើញដែរ ជំនាន់ហ្នឹងអត់បាយដោយខ្សែកពួកខ្ញុំបានរស់ ។

វណ្ណៈ បាទ!ចឹងមីងដូចថា ទៅដល់ភ្នំដងរែកហើយ ភ្នំដងរែកហ្នឹងនៅខាងអន្លង់វែងហ្នឹងឬមិនមែនទេ?

ឡៃ ភ្នំដងរែកហ្នឹងអន្លង់វែង កាលពីមុនមកខ្ញុំនៅហ្នឹងតើ នៅហ្នឹងបានមួយឆ្នាំហើយបានខ្ញុំមកតាមគ្រួសារខ្ញុំមកនៅគេផ្លាស់មកនៅកោះកុងហ្នឹង ។

វណ្ណៈ នៅអន្លង់វែងជាមួយ តា ម៉ុកអីហ្នឹង?

ឡៃ ចាស!ពីមុននៅអង្គភាពជាមួយ ប៉ុន្តែកងពលខុស ខ្ញុំនៅកងពល៦១២ កងពលតា ឈាន តា ហឿនហ្នឹង ។

វណ្ណៈ កាលហ្នឹងមកនៅខាងប៉ៃលិនវិញទេ បានមកនៅជាមួយ អ៊ី ឈាន?

ឡៃ នៅនោះនៅអត់ទេនៅជាមួយតាំងពីនោះមក ។

វណ្ណៈ ចឹងអ៊ី ឈានមុនដំបូងនៅនោះដែរ?

ឡៃ មិនមែនអ៊ី ឈាន មានតា ឈានមួយទៀត ។

វណ្ណៈ ចឹងតា ឈានផ្សេងទៀត?

ឡៃ ហ្នឹងហើយ ។

វណ្ណៈ ចឹងគេថាតា ០៥ ០៦អីនោះមីងមានស្គាល់ទេ?

ខ្លែះ  ០៥ ០៦ នោះមិនដឹងជាតាណាទេ ខ្ញុំអត់មានស្គាល់ ។

វណ្ណៈ  តា សារឿនអី?

ខ្លែះ  តា សារឿនមិនដែលស្គាល់មុខផង ដែលឬឈ្មោះមិនដែលស្គាល់មុខ ។

វណ្ណៈ  ចឹងមីងនៅអន្លង់វែងបានមួយឆ្នាំ?

ខ្លែះ  ចាស!ទំរាំឡើងមកដល់ផាប់អស់កាលហ្នឹង ដូចថាមានបាយ ហើយដូចថាដាច់ជាតិបាយហូប បាយ ហើយផាប់ក៏មានហូបផាប់ដោយសារបាយ ។

វណ្ណៈ  ឃ្លានពេក?

ខ្លែះ  ឃ្លានពេកហូបម៉ាទំហឹងជួនអីអ្នកខ្លះហូបហើយផាប់នៅលើអង្រឹង ។

វណ្ណៈ  បាទ ។

ខ្លែះ  ដេកព្រលឹមឡើង ។

វណ្ណៈ  ហល់ណឹង?

ខ្លែះ  ហល់បាយដាច់ជាតិបាយយូរ ។

វណ្ណៈ  បាទ!ចឹងកាលហ្នឹងមីងរៀបការនៅឆ្នាំណាទៅ?

ខ្លែះ  បើនិយាយទៅឆ្នាំ៨៣យួន ។

វណ្ណៈ  ការកាលហ្នឹងមានភ្ញៀវការឬចាប់គូរ?

ខ្លែះ  អូនអើយមានភ្ញៀវការអីណា ជំនាន់ហ្នឹងមិនមានភ្ញៀវការទេ មានដូចថាយើងមកចឹងពីរបីគូចឹង យើងអាចបានមិនមែនដូចមុន១០គូរបានការបាន៥គូរអីណាស់ ។

វណ្ណៈ  បាទ ។

ខ្លែះ  យើងសម្រេចចិត្តថាសុំ តែនិយាយទៅខ្ញុំជាមួយឪវាគ្រាន់តែស្រឡាញ់គ្នានោះចង់១០ឆ្នាំ ហើយ ។

វណ្ណៈ  ចឹងស្រឡាញ់តាំងមុននេះទៀត?

ខ្លែះ  ចាស ។

វណ្ណៈ  តាំងជំនាន់ខ្មែរក្រហមនោះ?

ខ្លែះ  ចាស!ហើយនិយាយទៅជំនាន់តស៊ូហ្នឹងគេថាយើងនៅក្មេង គេមិនទាន់ឲ្យទេ ទាល់អាយុ៣០អី នោះ ។

វណ្ណៈ  ចឹងមីងស្រឡាញ់គ្នាយូរហើយ?

ខ្លែះ  ចាស ។

វណ្ណៈ ប៉ុន្តែបើមីងការជំនាន់បីឆ្នាំវិញ មីងមិនអាចស្រឡាញ់តាមចិត្តបានទេ?

ឡៃៈ ចាស!តាមចិត្តអត់បានទេ ។

វណ្ណៈ គេចាប់ឲ្យតែក្រោយ៧៩មកឆ្នាំ៨០ដាងហ្នឹងយើងអាចស្រឡាញ់គ្នាយល់ចិត្តគ្នាបាន?

ឡៃៈ ចាស ។

វណ្ណៈ ចឹងអត់មានពីណាបង្ខំទេ?

ឡៃៈ អត់មានពីណាបង្ខំទេ យើងស្ម័គ្រចិត្តទៅ ។

វណ្ណៈ បាទ ។

ឡៃៈ មិនដូចមុនទេ ចាប់គូរដាក់តែម្តងក្នុងអង្គភាពមីងគិតទៅកន្លងមកគឺបែកបាក់គ្នាប៉ុន្មាននាក់ដែលហ្នឹង ប៉ុន្មានគូរដែលហ្នឹង យកមកអត់ត្រូវគ្នា អត់ត្រូវគ្នាចឹងគេយកទៅដាក់កន្លែងការដ្ឋាន ។

វណ្ណៈ បាទ ។

ឡៃៈ គេតាមដានយើង យើងរៀបហើយអីហើយក្នុងថ្ងៃហ្នឹងយប់ហ្នឹងគេចេះតែសង្កេតតាមមើល ។

វណ្ណៈ ហ្នឹងនិយាយក្នុងជំនាន់បីឆ្នាំវិញ?

ឡៃៈ ចាស!ជំនាន់បីឆ្នាំគេសង្កេតមើល បើចឹងគាត់ស្ម័គ្រចិត្តគ្នាគាត់ថាមិនអាចយកគ្នាបាន គាត់អត់ស្រឡាញ់ហើយខាងស្រីក៏អត់ ចឹងថាធ្វើម៉េចសុខចិត្តតែគាត់សម្លាប់ខ្លួនចោល ។

វណ្ណៈ មានដែលចឹង?

ឡៃៈ ចាស!សុខចិត្តសម្លាប់ខ្លួនចោលហើយចឹងក៏ជំនាន់ហ្នឹងក៏គេបានយោគយល់ចឹងឲ្យនៅរស់ហើយឲ្យទៅនៅការដ្ឋាន ។

វណ្ណៈ បាទ ។

ឡៃៈ ហើយខាងប្រុសគេបំបែកឲ្យទៅនៅទ័ពអីទៅ ។

វណ្ណៈ បាទ!ចឹងខ្លះក៏គេយោគយល់ដែរ?

ឡៃៈ ចាស ។

វណ្ណៈ គេអត់មានយកទោសយកពៃរ៍អីទេ?

ឡៃៈ ដោយសារយើងថាសុខចិត្តស៊ូស្លាប់ ។

វណ្ណៈ បាទ ។

ឡៃៈ សុខចិត្តស៊ូស្លាប់ថាមិនអាចយកគ្នាបាន ព្រោះគេស្ម័គ្រចិត្តចឹងខាងស្រីក៏ស្ម័គ្រចឹងអត់ឲ្យយកគ្នាបានទេ ចឹងក៏គាត់ថាឥឡូវមានទិសដៅមួយបញ្ជូនទៅនៅការដ្ឋានទៅ ។

វណ្ណៈ បាទ ។

ឡៃ៖ មានអ្នកខ្លះថាអត់ត្រូវគ្នាមានអ្នកស្លាប់ដែលអូន ។

វណ្ណៈ បាទ ។

ឡៃ៖ សម្លាប់ខ្លួនឯងក៏មានដែរ ។

វណ្ណៈ បាទ! ខ្លះក្រោយ៧៩ បានលែងគ្នាវិញក៏មានដែរ?

ឡៃ៖ ចាស! ហ្នឹងហើយប៉ុន្តែកាលហ្នឹងដូចថា ការស្រឡាញ់មិនមែនបានស្រឡាញ់ដូចថាទ័ពចិនណាស់ មករើសដូចថាក្នុងក្រសួងមន្ទីរចិន គេមកឃើញចង្អុលអ្នកណាអ្នកហ្នឹងទៅក៏រើសគូរឲ្យចិនទៅ ឧទាហរណ៍នៅអង្គភាពខ្ញុំ ខ្ញុំធ្លាប់ឃើញថា មកចិនបង១គាត់អាយុចាស់ហើយចិនណាស់ មានខាងបង១ខាងយោធាខាងទ័ពអីហ្នឹងគេមកមើលចិនទៅ ហើយរវាងអង្គភាពនិងអង្គភាពរបស់គេខាងយុទ្ធជនហ្នឹងខាងក្រសួងមន្ទីរហ្នឹង គេមកសួរចិនទៅឲ្យរើសទៅគូរមួយអ្នកនេះអ្នកនោះ ខ្លះទៅតាមស្ម័គ្រចិត្តដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ ស្ម័គ្រចិត្តយកចិនទៅ តែអ្នកខ្លះអត់ទេចាប់ដាក់តែម្តង ។

វណ្ណៈ ចិនចាប់ដាក់ច្រើនមិនត្រូវចិត្ត?

ឡៃ៖ មិនត្រូវទេ ។

វណ្ណៈ ចិនមីងកាលជំនាន់ហ្នឹងបីឆ្នាំហ្នឹងមីងមានដឹងថាគេសម្លាប់មនុស្ស ប្រជាជនអត់មានអាហារអីមានដឹងទេ កាលហ្នឹង?

ឡៃ៖ និយាយទៅខ្ញុំចេញមកនៅក្រសួងមន្ទីរដឹងភាគច្រើនគឺខ្ញុំចុះទៅតាមសហករណ៍ដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ និយាយទៅសហករណ៍ម៉ាដូរ ដូចខ្ញុំនិយាយក្រោយខាងព្រែកព្រះសព្វអីពិបាកវេទនាខ្លាំងជាងគេណាស់ បើទៅខាងខ្ញុំ ខ្ញុំធ្លាប់ឃើញដែលតែវាមិនដឹងរាល់ថ្ងៃព្រោះខ្ញុំនៅមន្ទីរណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ យូរៗខ្ញុំចុះទៅម្តង ចុះទៅការដ្ឋានទៅរកបន្លែសុំបន្លែគាត់តាមភូមិ ឧទាហរណ៍ដូចជាល្ពុង ។

វណ្ណៈ បាទ ។

ឡៃ៖ ហើយបន្លែរ៉ៃណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ សម្រាប់យកមកឲ្យអ្នកជំងឺហូបចិនប្រចាំថ្ងៃចិនហើយក្នុងមន្ទីរខ្លួនឯងហ្នឹងក៏ខំប្រឹងដាំដល់ចុងបំផុតបន្លែរកមិនបានបុកម្លូអំបិលឲ្យអ្នកជំងឺហូប ។

វណ្ណៈ	បាទ!ចឹងខាងផ្នែកពេទ្យចុះទៅជួបប្រធានសហករណ៍ប្រធានកងប្រធានអីចឹងគេស្វាគមន៍យើង ដែលឬក៏គេមិនសូវស្វាគមន៍ទេ?

ឡៃ:	គេជួយយើងតើអូន ។

វណ្ណៈ	ចឹងគេជួយដែរ?

ឡៃ:	ចាស!ឲ្យយើងទាក់ទងគេបានតិចច្រើនក៏បាន ។

វណ្ណៈ	ចឹងមានសំបុត្រមានអីដែលកាលហ្នឹង?

ឡៃ:	កាលទៅហ្នឹងអី ។

វណ្ណៈ	បាទ ។

ឡៃ:	អត់មានទេ គេទំនាក់ទំនងជូនអីមានសំបុត្រជូនអីអត់អាងយើងស្គាល់ដែលហ្នឹង ។

វណ្ណៈ	បាទ ។

ឡៃ:	ដល់យើងស្គាល់ទៅមិនបាច់សំបុត្រស្នាមអីទេ ។

វណ្ណៈ	បាទ ។

ឡៃ:	គាត់ជួយឧបត្ថម្ភយើង ។

វណ្ណៈ	ចឹងឲ្យតែទៅគេស្គាល់ថាផ្នែកពេទ្យពីខេត្តមកចឹងហើយ?

ឡៃ:	ចាស ។

វណ្ណៈ	ចឹងមីងទៅដល់ឃើញប្រជាជនធ្វើការហូបបបរអីចឹងផ្ទាល់ផ្នែកដែរ?

ឡៃ:	ចាស!ភាគច្រើនទៅខាងខ្ញុំដូចជាមិនទាន់បានដឹងថា តែមកដល់ឆ្នាំ៧៩នេះខ្ញុំជម្លៀសមកពីខេត្ត ខ្ញុំមក មកពីខេត្តក្រចេះអីចឹងនៅព្រែកប្រសព្វ ។

វណ្ណៈ	បាទ ។

ឡៃ:	ពុស្សវស្សាកាលហ្នឹងវារគេរគោកអន្តភាពរបស់ខ្ញុំនិយាយទៅវត់ជងទៅនៅវត្ត ។

វណ្ណៈ	បាទ ។

ឡៃ:	វត្តព្រែកប្រសព្វហ្នឹងគិតទៅប្រជាជនគាត់យ៉ាប់ឃើនមែនទែនអ្នកខ្វះបបរមួយវែកៗហើយបបរ រាវទៀត ។

វណ្ណៈ	បាទ!ចឹងមីងគិតមើលថាជំនាន់ហ្នឹងធ្វើស្រូវអត់បានឬមួយយ៉ាងម៉េចបុគេមិនចង់ឲ្យយើងហូប កាលហ្នឹង?

ឡៃ:	បើនិយាយទៅស្រូវរាប់តោន ប្រជាជនគាត់ធ្វើបានណាស់ និយាយតាមទំនប់តាមប្រឡាយ ប្រជាជនមិនមានអ្នកណាថាខ្សិលបាននៅផ្ទះអត់ ។

វណ្ណៈ បាទ ។

ឡៃ៖ ហើយមិនអត់ទេ ស្រូវតែមិនដឹងជាយ៉ាងម៉េចខ្ញុំមិនដឹងដែរ មិនដឹងជាគេយកចេញទៅណាវ៉ា មិនដឹងដែរ ខ្ញុំដឹងថាស្រូវធ្វើបានតាមសូម្បីតែខាងស្រែខាងស្រុកភូមិម៉ែខ្ញុំគាត់ធ្វើបានព្រោះគាត់នៅកន្លែងមណ្ឌលកុមារ សូម្បីតែម្ដាយខ្ញុំគាត់ចាស់ហ្នឹងគាត់នៅខាងថែទាំកុមារដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ ខាងដាំបាយឲ្យកូនក្មេងសិស្សហ្នឹងណាស់ តូចៗហ្នឹងមើលដាំបាយឲ្យហូបចឹងទៅ ចោលផ្ទះចោលសំបែងនៅជីដូចខ្ញុំចាស់ហ្នឹង គាត់ជរាដែរ គាត់វង្វេងហើយ ល្ងាចឡើងចឹងទៅបានទៅដេកផ្ទះចឹងទៅ ថ្ងៃហ្នឹងដូចថាខ្ញុំទៅពីមន្ទីរហ្នឹងទៅ ទៅរកបន្ទៃខ្ញុំឈានចូលផ្ទះហ្នឹងម៉ែខ្ញុំគាត់នៅកន្លែងមន្ទីរកុមារហ្នឹង ខ្ញុំក៏មិនដែលដឹងដែរថា គាត់ហ្នឹងធ្វើស្អីក៏មិនដែលដឹងដែរ ពេលហ្នឹងបានដឹងថា និយាយទៅក្រុមគ្រួសារខ្ញុំបែកបាក់អស់ ។

វណ្ណៈ បាទ ។

ឡៃ៖ ប្អូនខ្ញុំក៏អត់ទៅគេគៀងទៅនៅទំពអស់ ហើយឪពុកម្ដាយខ្ញុំគាត់ចាស់ៗហើយគេប្រើឲ្យគ្រប់គ្រងខាងដាំបាយដាំទឹកអីណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ តែកុមារហ្នឹងទៅ ហើយជីដូនខ្ញុំនៅផ្ទះតែម្នាក់ឯងទេ ហើយគាត់ចាស់គាត់វង្វេងហើយ ។

វណ្ណៈ បាទ ។

ឡៃ៖ ឃើញខ្ញុំទៅហ្នឹងគាត់មិនស្គាល់ខ្ញុំទៀត គាត់សួរខ្ញុំគាត់ដើរជុំវិញផ្ទះគាត់រកជ្រូវឡើងផ្ទះអត់ឃើញ ខ្ញុំសួរជីដូនថា យាយដើររកអី អញរកផ្ទះណា គាត់សួរថាឯងកូនពីណាគេ ទាល់ប្រាប់បានដឹង ។

វណ្ណៈ បាទ ។

ឡៃ៖ ដល់ចឹងទៅជូនគាត់ឡើងផ្ទះចឹងទៅ ។

វណ្ណៈ បាទ!ចឹងមីងកាលជំនាន់ហ្នឹងមីងគិតថា ខាងសហករណ៍មិនចង់ឲ្យយើងហូបប្លុមួយខាងថ្នាក់លើដាក់បញ្ជាមកប្លុមួយយ៉ាងម៉េចមីងកាលហ្នឹង មីងអាចដឹងបានទេ?

ឡៃ៖ មិនដឹងយ៉ាងម៉េចអូន មិនដែលចាប់អារម្មណ៍ប្លុមួយគេកំណត់ តាមនិយាយទៅបែបគេកំណត់ឲ្យតែម្ដងនិយាយមិនដឹងជាពីក្រោមមិនដឹងពីលើ ព្រោះថានិយាយទៅតំបន់ខ្ញុំដូចថាមានអ្នកក្បត់ច្រើនតែម្ដង ។

វណ្ណៈ ក្បត់យ៉ាងម៉េចមីង?

ឡៃ៖	ក្បត់ខុទាហរណ៍ថា អ្នកនេះមកចឹងទៅគ្រប់គ្រងដូចថាខាងតាកែវឈ្មោះអីចឹងមកមួយសារចឹង ទៅថាអ្នកហ្នឹងក្បត់ ហកផ្លាស់អ្នកហ្នឹងចេញទៅអ្នកក្រោយមកដូចគ្នាដដែល ។

វណ្ណៈ	ចឹង?

ឡៃ៖	ចាស!ដូចតែគ្នាផ្លាស់ឡើងពីរបីដំណាក់ហើយ ។

វណ្ណៈ	ចឹងយកគ្នាទៅសម្លាប់បន្តៗគ្នា?

ឡៃ៖	ចាស ។

វណ្ណៈ	មួយចោទថាមួយក្បត់មួយៗ?

ឡៃ៖	ហ្នឹងហើយ ។

វណ្ណៈ	ចឹងខ្ញុំចង់សួរបកទៅកាលមីងរត់៧៩ទៅអន្លង់វែង មីងចេញពីអន្លង់វែងមីងទៅខាងណាទៀតដែរ?

ឡៃ៖	ខ្ញុំនិយាយទៅ ចេញពីអន្លង់វែងមកហ្នឹងតែម្ដងអូន មកម៉ាជួរកោះកុងហ្នឹងតែម្ដង ។

វណ្ណៈ	មកកោះកុង?

ឡៃ៖	ចាស!កាលជំនាន់ហ្នឹងខ្ញុំមានកូនស្រីខ្ញុំមួយ ។

វណ្ណៈ	បាទ ។

ឡៃ៖	កាលហ្នឹងមានទម្ងន់បីខែក្នុងផ្ទៃហើយរហូតដល់កូនកើតមកអត់បានមួយខួបពីរខែបានជួបប្ដី ។

វណ្ណៈ	បាទ ។

ឡៃ៖	កាលជំនាន់ហ្នឹងយួនបុកពីព្រំដែនទៅដល់ថៃ ។

វណ្ណៈ	បាទ ។

ឡៃ៖	ចឹងខ្ញុំសម្រាលកូនតែឯង មានតែញាតិអ្នកស្រុកអ្នកភូមិនៅជាមួយគ្នាហ្នឹងជួយយកអាសារគ្នា ចំណែកប្ដីគេយកមកនេះមកវៃនៅម៉ាជួរកោះកុងហ្នឹង ។

វណ្ណៈ	វៃជាមួយយួនកាលហ្នឹង?

ឡៃ៖	ចាស ។

វណ្ណៈ	ចឹងមីងរៀបការហើយគេឲ្យនៅក្រោយប្ដីគេឲ្យទៅមុខទៀត?

ឡៃ៖	ចាស!កាលហ្នឹងការបានតែមួយអាទិត្យគេឲ្យទៅមុខហើយ គេមិនឲ្យនៅផ្ទះយូរទេជួនអីកន្លះឆ្នាំ ៦ខែទៅជួនអីមួយឆ្នាំជាងចឹងទៅ បើខ្ញុំគិតទៅវាពីរឆ្នាំជាងនោះបាន១ជួបគ្នា ។

វណ្ណៈ	បាទ ។

ឡៃ៖ និយាយទៅតាំងពីកូនមានក្នុងផ្ទៃបីខែរហូតដល់កូនកើតបានមួយខួបពីរអូនឯងគិតទៅប៉ុន្មានឆ្នាំដែរ ។

វណ្ណៈ ចឹងកាលហ្នឹងប្តីទៅសមរភូមិមុខ?

ឡៃ៖ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងតស៊ូរៃជាមួយយួនចឹងយើងអត់មានប្រាក់ខែអីទេ?

ឡៃ៖ អត់មានទេ ប្តីនៅមុខហើយជូនអីប្រពន្ធនៅក្រោយហ្នឹងលីគ្រាប់ ។

វណ្ណៈ ចឹងប្រពន្ធលីគ្រាប់ទៀត?

ឡៃ៖ ចាស!ឧទាហរណ៍ថា ប្រពន្ធអត់មានកូនមានអីនៅលីវណាស់ មិនទាន់មានកូនណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ ឬមួយដូចជាកូនធំដូចថា កូនអាយុបាន៧ឆ្នាំហើយហ្នឹងក៏គេឲ្យយើងទៅលីគ្រាប់ដែរ ។

វណ្ណៈ បាទ ។

ឡៃ៖ លីគ្រាប់យកទៅដាក់ជួភ្នំចឹងណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ ចាស!យើងលីទៅដាក់លើភ្នំចឹងដូចថាឡានដឹកពីក្រោមចឹងទៅដល់ជើងភ្នំចឹងយើងលីឡើងដាក់ឲ្យគេលើភ្នំចឹងទៅ ។

វណ្ណៈ បាទ ។

ឡៃ៖ ហើយយើងមកវិញហ្នឹងងាប់រស់អីចេះតែផ្សងប្រេងទៅគេឲ្យទៅជាវិន័យរបស់គេតែម្តង ។

វណ្ណៈ បាទ ។

ឡៃ៖ បើសិនជាយើងមិនទៅគេចាត់ទុកថាយើងហ្នឹងអត់ល្អ ។

វណ្ណៈ បាទ!ចឹងនៅខាងកោះកុងហ្នឹងពីណាជាប្រធានកងពលក្រោយ៧៩ហ្នឹង?

ឡៃ៖ និយាយទៅខាងកោះកុងពីណាទេអូនខ្ញុំអត់ស្គាល់ ខ្ញុំអត់ស្គាល់គេខ្ញុំមកនៅជ្រុកជាមួយគេ ។

វណ្ណៈ បាទ ។

ឡៃ៖ បើនិយាយទៅកងពលហ្នឹងកងពលពូឈានដដែលហ្នឹង មកពីកងពីនោះមកផ្លាស់មកហ្នឹងតែម្តងហ្នឹង ។

វណ្ណៈ បាទ!ចឹងដែលបានជួបតា ប៉ុល ពតអីទេ?

ឡៃ៖ អត់ទេ ។

វណ្ណៈ បាទ ។

ឡៃ្ម: មិនដែលស្គាល់មុខទៀតផងទេខ្ញុំ ទើបស្គាល់តាមគេថតហ្នឹងណាស់ ។

វណ្ណៈ បាទ!ចឹងមីងមានដែលចូលដល់ជំរុំថៃទេ?

ឡៃ្ម: ជំរុំថៃនៅម៉ាដួរគេហៅស្តីទេ នៅជំរុំភ្លេចបាត់ហើយជំរុំហ្នឹងនោះ ។

វណ្ណៈ ធ្លាប់ចូលដល់ថៃដែរ?

ឡៃ្ម: នៅជាប់ព្រំដែនថៃ ។

វណ្ណៈ ចឹងកាលហ្នឹងមីងហេតុអីមិនចង់រត់ទៅប្រទេសក្រៅអី?

ឡៃ្ម: អត់ហ៊ានទេ អត់ដែលស្គាល់គេយើងអត់ចេះភាសាគេផង ។

វណ្ណៈ បាទ ។

ឡៃ្ម: ខ្លាចព្រួវៗគេល្បីថាយកទៅធ្វើអីៗ ៗផាប់រស់អីចេះតែមិនចង់ចេញពីស្រុកខ្មែរហ្នឹងណាស់ បើសិនជាចិត្តដាច់ដូចគេទៅនៅស្រុកថៃស្រុកអីខ្លាចលោគេធ្វើបាបចេះតែនៅទ្រាំត្រែង ។

វណ្ណៈ បាទ ។

ឡៃ្ម: ខ្លាចមិនទុកចិត្ត ។

វណ្ណៈ យើងមើលមិនឃើញ?

ឡៃ្ម: មើលអត់ឃើញសាសន៍គេ សាសន៍យើងនៅមានផាប់រស់ទំរាំសាសន៍គេនិយាយស្តាប់គ្នាមិនបាន ។

វណ្ណៈ ចឹងនៅពេលមីងនៅកោះកុងហើយដល់ក្រោយមកទៀតមីងនៅណាទៀតមីងនៅប៉ុន្មានឆ្នាំ?

ឡៃ្ម: និយាយទៅខ្ញុំនៅម៉ាដួរជំរុំសាយខេអីគេហ្នឹង ជំរុំសាយខេហ្នឹង ។

វណ្ណៈ មិនមែនសាយអេកទេ សាយខេ?

ឡៃ្ម: សាយខេ សាយធូអីហ្នឹងជាប់ៗគ្នាជំរុំ គេហៅជំរុំសុខសាន្តពូ លោកគ្រូខ្ញុំនៅជំរុំសាយខេហ្នឹងបានមួយរយៈដែលក្រោយមកក៏អន្តភាពគេហ្នឹងទៅយកមក ។

វណ្ណៈ បាទ ។

ឡៃ្ម: ព្រោះគេទៅយកកំលាំងមកវៃអីចឹង និយាយទៅគេមិនឲ្យយើងចេញ ។

វណ្ណៈ បាទ ។

ឡៃ្ម: ចេញទៅនៅតាមជំរុំគេ ។

វណ្ណៈ បាទ ។

ឡៃ្ម: ខ្លាចយើងរត់ យើងរត់ទៅតាមថៃទៅនៅស្រុកខ្មែរវិញគេបញ្ជូនមកហ្នឹងគេឲ្យយើងទៅទាក់ទងជាមួយខាងពួកជំរុំគេ ។

វណ្ណៈ ចឹងមីងអត់បានទៅនៅជុំទេ?

ឡៃ្ឡៈ ខ្ញុំទៅនៅបានប្រហែលជាមួយខែ កាលសភាពការណ៍យួនបុកខ្លាំងយើងនៅហ្នឹង ហើយក្រោយមកគេប្រមូលមកនៅតាមអគ្គភាពវិញ ។

វណ្ណៈ នៅពេលយួនវ៉ៃខ្លាំង?

ឡៃ្ឡៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមីងមានដឹងថា ទាហានខ្មែរខាងខ្មែរក្រហមអីស្លាប់ច្រើនទេ កាលដែលវ៉ៃជាមួយយួន?

ឡៃ្ឡៈ និយាយទៅវាមាន ។

វណ្ណៈ ស្លាប់ទាំងសងខាង?

ឡៃ្ឡៈ ស្លាប់ទាំងសងខាងកាលច្បាំងគ្នាវាមិនអត់ទេ តែគ្រាន់ថាយើងវ៉ៃឈ្លបមិនស្លាប់អីគដើងគ្នាព្រោះទ័ពវាតិច ចល័តលិចកើតប៉េះប៉ោះទៅវាមិនសូវប៉ុន្មាន ។

វណ្ណៈ យួនមានស្លាប់ច្រើនដែរ?

ឡៃ្ឡៈ ចាស!វ៉ៃឈ្លបហ្នឹងវាពិបាករកណាស់ ។

វណ្ណៈ ចឹងមីងឆ្នាំណាបានមីងត្រឡប់មកនេះ?

ឡៃ្ឡៈ ខ្ញុំចុះមកនេះចុះមកឆ្នាំមើលគិតសិនឆ្នាំ.. ។

វណ្ណៈ សមាហរណ៍កម្មហើយ?

ឡៃ្ឡៈ ឆ្នាំ៩៨អូន ។

វណ្ណៈ សមាហរណ៍កម្មហើយ?

ឡៃ្ឡៈ ចាស!៩៨ ។

វណ្ណៈ មកនៅភូមិនេះតែម្តង?

ឡៃ្ឡៈ ចាស!មកនៅភូមិនេះតែម្តង ចុះមក មកនៅហ្នឹងប៉ុន្តែឆ្នាំជំនាន់អ៊ុនគាក់នោះ ខ្ញុំនៅសំឡូត ។

វណ្ណៈ ឆ្នាំណា?

ឡៃ្ឡៈ ឆ្នាំ៩៣ នៅសំឡូតមកសារទៅយើងហាក់គេបញ្ជូនយើងទៅមួយសារទៀតនោះ ត្រឡប់មួយសារទៀតទៅ ។

វណ្ណៈ ចឹង៩៨មកនៅនេះតែម្តង?

ឡៃ្ឡៈ ចាស ។

វណ្ណៈ មកនៅនេះដំបូងមិនទាន់មានផ្ទះមានសំបែងទេ?

ឡៃ៖ និយាយទៅសុទ្ធតែព្រៃទាំងអស់ សូម្បីតែដើរមិនហ៊ានដើរ ដើរតែតាមការស្រមើស្រមៃកន្លែងផ្លូវនេះធំវាគ្រោះថ្នាក់ប្រថុយនិងគ្រោះថ្នាក់ច្រើនណាស់ ព្រោះផ្លូវនេះផ្លូវ៥៦ជំនាន់សង្គ្រាមដាក់មីនដាក់អី ។

វណ្ណៈ មានមីន?

ឡៃ៖ ចាស!ចឹងការរុករកអីក៏មិនទាន់ហ៊ានដែលដំបូងក៏មានដូចថាឈ្លបមានខាងទ័ពហ្នឹងគេដើរចូកនិងប៉ែលនិងរាវ របៀបរាវមីនយកប៉ែលចូកមានរបស់អីសម្រាប់រាវ ។

វណ្ណៈ ចឹងកាលមីងមកដល់ដំបូងហ្នឹងមានសត្វច្រើន គេមានមានដីរអីមានទេ?

ឡៃ៖ ចាស!ដីរមានដែលមិនអត់ទេ កន្លែងហ្នឹងមាននៅជើងភ្នំប៉ុន្តែឥឡូវដូចថាវាលែងនៅវា វាលអស់ហើយ ។

វណ្ណៈ ចឹងវាលអត់ហើយ?

ឡៃ៖ ចាស!មានឆ្លងកាត់មានម៉ាផ្លូវភ្នំខ្មោចភ្នំអីទេ ។

វណ្ណៈ បាទ!ចឹងខ្ញុំចង់សួរមីងបន្តិចទៀតដែរ មីងគិតថាសម័យសង្គ្រាមហើយនិងសម័យឥឡូវហ្នឹងមីងគិតថាមួយណាស្រួលជាងមួយណា មីងនិយាយតាមការពិត និយាយតាមត្រង់?

ឡៃ៖ ចាស!អូនឯងចង់បានធ្វើអីសង្គ្រាមនិយាយទៅខ្មែរយើងសង្គ្រាមរាប់មិនឈ្នះទេ ។

វណ្ណៈ បាទ ។

ឡៃ៖ ជំនាន់ខ្ញុំហ្នឹងប៉ុន្មានគ្រឡប់ហើយ ។

វណ្ណៈ បាទ ។

ឡៃ៖ ហើយឥឡូវហ្នឹងខ្ញុំព្រួសួរថាថៃជាមួយខ្មែរទៀតខ្ញុំថាកុំឲ្យកើតមានអី ព្រោះថាអត់ឃ្លានមានស៊ីយើងនៅមួយកន្លែងយើងរកបានហូបអូន ។

វណ្ណៈ បាទ!វាចឹងហើយ ។

ឡៃ៖ ព្រោះការទ្រឡប់ចុះគ្រឡប់ឡើងហ្នឹងវាគ្មានទេ ខ្ញុំធ្លាប់ហើយមានតែខ្លួនទេ ប៉ុន្តែខ្ញុំជួបជុំគ្រួសារវាមិនបាត់បង់ប្តីបាត់បង់កូនចៅអី ខ្ញុំប៉ុណ្ណឹងគិតថាមានសេចក្តីសុខហើយមិនចង់បានទេសង្គ្រាមអត់ឃ្លានមានស៊ីខ្ញុំនៅហ្នឹងកន្លែងណាអូនណាស់ ។

វណ្ណៈ បាទ ។

ឡៃ៖ យើងដាំយើងដុះយើងរកស៊ីទៅតាមកំលាំងយើងមានក៏មានទៅយើងអត់យើងបានត្រឹមម៉ាររស់តាមផលបុណ្យរបស់យើង យើងសាងទៅ ។

វណ្ណៈ	បាទ!មីងចង់សួរបន្តិចទៀត ដូចថាមីងរាល់ថ្ងៃហ្នឹងមីងមានដែលឃើញគេកាត់ទោសអីមីងមានដែលបានមើលអីដែរ?

ឡៃ:	អត់ដែលបានមើលតាមទូរទស្សន៍អីផង ។

វណ្ណៈ	ចឹងមីងមកដល់សម័យឥឡូវនេះដូចថាសម័យតា ប៉ុល ពត តា អៀង សារី តា នួន ជា តាខៀវ សំផនអីបានធ្វើឲ្យបាត់បង់មនុស្សជាច្រើននាក់ ថាជាងមួយលាននាក់ចុះ ចឹងដោយសារថាប្រទេសយើងចូលក្នុងអន្តការសម័យប្រជាជាតិដែរ?

ឡៃ:	ចាស ។

វណ្ណៈ	ចឹងគេតម្រូវឲ្យមានការកាត់ទោសអីចឹង ចឹងមីងគិតថាកាត់ទោសថ្នាក់ដឹកនាំកំពូលធំៗប៉ុន្មាននាក់ហ្នឹងវាជាការខុសឆ្គងឬមួយជាការត្រឹមត្រូវបើតាមយោបល់មីងគិត?

ឡៃ:	អាហ្នឹងនិយាយតាមច្បាប់អាហ្នឹងត្រឹមត្រូវហើយ បើនិយាយតាមច្បាប់ពីមុនវាព្រៃនិយាយទៅវាអាងតែអំណាច ថាអំណាចគ្រប់ដណ្តប់និយាយទៅគាត់អាងជាជំនួយការរបស់គេ ។

វណ្ណៈ	បាទ ។

ឡៃ:	គេរាយការណ៍ទៅថាល្អៗទៅថាម៉េចថាចឹងហើយគាត់មិនដែលចុះមកពិនិត្យតាមហើយតាមការរាយការណ៍របស់គេវាក្រោមៗធ្វើបាបប្រជារាស្ត្រយើងអត់ដឹងទេ ។

វណ្ណៈ	បាទ ។

ឡៃ:	ហ្នឹងសមគាត់បានទទួលផលដែលគាត់បានសាងហ្នឹងហើយ ។

វណ្ណៈ	បាទ!ព្រោះគាត់ជាមេឪដែលគាត់មិនបានមើលកូនចៅផ្ទាល់?

ឡៃ:	ចាស!ជាមិនបានមកមើលគាត់ជាមេឪ ដូចថាកូនចៅនៅក្រោមដូចថាគាត់មានហូបគ្រប់គ្រាន់គាត់នៅតែនោះគាត់នៅតែបបញ្ជានោះ ដឹងថាកូនចៅនៅក្រោមអត់ឃ្មានឬក៏លំបាកគេធ្វើបាបធ្វើទុកធ្វើទោសអីគាត់អត់ដឹង ។

វណ្ណៈ	បាទ ។

ឡៃ:	ស្តាប់តែការរាយការណ៍របស់គេអត់ជាក់ស្តែង ។

វណ្ណៈ	បាទ ។

ឡៃ:	ខ្លួនឯងអត់ដឹង ។

វណ្ណៈ	ចឹងមីងមានអីចង់បន្ថែមដែលខ្ញុំមិនបានសួរមីង?

ឡៃ:	ចាស!អត់មានអីបន្ថែមទេអូន និយាយទៅវាសមស្របអ៊ីដែលគាត់ធ្វើដែលគាត់សាងមកវាមិនបានគិតណាស់ ។

វណ្ណៈ	បាទ ។

ឡៃ្សះ	មិនបានគិតឲ្យបានវែងឆ្ងាយនឹកឃើញថាកសាង១កសាងហ្នឹងវាហួសហេតុពេកវាចេញអាបញ្ហាហ្នឹងហើយ ។

វណ្ណៈ	បាទ ។

ឡៃ្សះ	ប្រើមនុស្សដូចគោយន្តដូចគ្រឿងម៉ាស៊ីន ជំនាន់ហ្នឹងអូនឯងដឹងស្រាប់ហើយធ្វើការងារទាល់តែយប់ ។

វណ្ណៈ	បាទ ។

ឡៃ្សះ	ខ្ញុំមិនបានធ្វើដាក់ស្តែងខ្លួនឯងទេ តាមភូមិតាមស្រុកអ៊ីពុគាត់និយាយថាវាចឹងមែនហ្នឹង ។

វណ្ណៈ	បាទ ។

ឡៃ្សះ	ប្រើមនុស្សហួសប្រម៉ាន់ជាទារុណកម្ម ។

វណ្ណៈ	បាទ ។

ឡៃ្សះ	ដាក់ទារុណកម្មគាត់ ។

វណ្ណៈ	ចឹងខ្ញុំអរគុណមីងច្រើនហើយណាស់ ។

ឡៃ្សះ	ចាស ។

**ចប់**